សាលាដំបូងខេត្តសៀមរាប
តុលាការរដ្ឋប្បវេណី
សំណុំរឿងរដ្ឋប្បវេណីលេខៈ ៤៧២
ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ២០២៣
សាលក្រមលេខៈ ២០ (ញ)/២៧៧
ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០២៤

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# សាលក្រម
## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តសៀមរាប

**ចៅក្រមជំនុំជម្រះ**

លោក [redacted] ជាចៅក្រមនៃសាលាដំបូងខេត្តសៀមរាប

**ក្រឡាបញ្ជី**

លោកស្រី [redacted] ជាក្រឡាបញ្ជីនៃសាលាដំបូងខេត្តសៀមរាប

**ក- ឈ្មោះ និង អាសយដ្ឋានរបស់គាគី**

**ដើមចោទ** ៖ ឈ្មោះ [redacted] ឡៃហ៊ាង ភេទស្រី អាយុ២៩ឆ្នាំ ជាតិខ្មែរ មានអាសយដ្ឋាន[redacted]។

អ្នកតំណាងដោយអណត្តិ: លោកមេធាវី [redacted] អត្តលេខ:២៥៨៦T មានអាសយដ្ឋានស្ថិតនៅ អាគារលេខ:[redacted]

**សហចុងចម្លើយ** ៖ ឈ្មោះ[redacted]ចន្ទី ភេទប្រុស កើតថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ១៩៦៧ សញ្ជាតិខ្មែរ និងប្រពន្ធឈ្មោះ [redacted]សៀកហ៊ិន ភេទស្រី កើតថ្ងៃទី១៤ ខែមករា ឆ្នាំ១៩៦៦ ជនជាតិខ្មែរ មានអាសយដ្ឋានស្ថិត [redacted] ។

អ្នកតំណាងដោយអណត្តិ: លោកមេធាវី[redacted]អត្តលេខ:២៥៨៦T ការិយាល័យមេធាវី[redacted]មានអាសយដ្ឋានស្ថិតនៅផ្ទះលេខ: [redacted]។

**ខ- ខ្លឹមសារនៃសាលក្រម ដែលដើមចោទទាមទារឲ្យតុលាការចេញ**

ក. បង្គាប់ឲ្យចុងចម្លើយប្រគល់ការកាន់កាប់ដីធ្លី - ផ្ទះមួយកន្លែងដែលមានទំហំ៥៥០ម៉ែត្រការ៉េ ជាប្រភេទដីលំនៅឋាន ដែលមានព្រំប្រទល់ខាងជើងទល់នឹងឈ្មោះ [redacted] សូនី ខាងត្បូងទល់នឹងចំណីផ្លូវជាតិលេខ៦៧បី ខាងកើតទល់នឹងឈ្មោះ[redacted]ចាន់ធី ខាងលិចទល់នឹងឈ្មោះ [redacted]ម៉ារី មានទីតាំងស្ថិតនៅភូមិវត្ត ឃុំស្រែណូយ ស្រុកវ៉ារិន ខេត្តសៀមរាប ប្រគល់ទៅឲ្យដើមចោទឈ្មោះ[redacted]ឡៃហ៊ាង។

ខ. បង្គាប់ឲ្យចុងចម្លើយធ្វើនីតិវិធីផ្ទេរការកាន់កាប់ដីធ្លី-ផ្ទះមួយកន្លែងដែលមានទំហំ៥៥០ម៉ែត្រការ៉េ ជាប្រភេទដីលំនៅឋាន ដែលមានព្រំប្រទល់ខាងជើងទល់នឹងឈ្មោះ [redacted] សូនី ខាងត្បូងទល់នឹងចំណីផ្លូវជាតិលេខ៦៧បី ខាងកើតទល់ឈ្មោះ[redacted]ចាន់ធី ខាងលិចទល់នឹងឈ្មោះ [redacted]ម៉ារី មានទីតាំងស្ថិតនៅភូមិវត្ត ឃុំស្រែណូយ ស្រុកវ៉ារិន ខេត្តសៀមរាប ប្រគល់ទៅឲ្យដើមចោទឈ្មោះ[redacted] ឡៃហ៊ាង។

គ. បង្គាប់ឲ្យចុងចម្លើយសងសំណងនៃការខូចខាត និងសងជំងឺចិត្តចំនួន ៥.០០០ (ប្រាំពាន់) ដុល្លារអាមេរិក ប្រគល់ទៅឲ្យដើមចោទឈ្មោះ[redacted] ឡៃហ៊ាង។



Scanned with CamScanner

ឃ. ប្រាក់ប្រដាប់ក្តី ជាបន្ទុករបស់ចុងចម្លើយ។

**គ- អង្គហេតុ**

ដើមចោទឈ្មោះ [redacted] ខ្មែរហ៊ាង ត្រូវជាអតីតកូនប្រសាររបស់សហចុងចម្លើយឈ្មោះ [redacted] ចន្ទី និងប្រពន្ធឈ្មោះ [redacted] សៀកហ៊ិន។ ដើមចោទ បានរៀបអាពាហ៍ពិពាហ៍ជាមួយកូនប្រុសរបស់សហចុងចម្លើយឈ្មោះ [redacted] ចាន់ពេជ្រ ប៉ុន្តែ ក្រោយមក ដើមចោទ និងកូនរបស់សហចុងចម្លើយ បានលែងលះគ្នា ដោយតុលាការបានចេញសាលក្រមសម្រេចឲ្យលែងលះ។ ដើមចោទអះអាងថា ក្រោយពេលរៀបអាពាហ៍ពិពាហ៍រួច និងមុនពេលលែងលះគ្នាជាមួយអតីតប្តីឈ្មោះ [redacted] ចាន់ពេជ្រ, សហចុងចម្លើយឈ្មោះ [redacted] ចន្ទី និងប្រពន្ធឈ្មោះ [redacted] សៀកហ៊ិន ដែលជាអតីតឪពុកម្តាយក្មេក បានចែកដីធ្លីមួយកន្លែងដែលមានទំហំ៥៥០ម៉ែត្រការ៉េ ជាប្រភេទដីលំនៅឋាន ដែលមានព្រំប្រទល់ខាងជើងទល់នឹងឈ្មោះ [redacted] សូនី ខាងត្បូងទល់នឹងចំណីផ្លូវជាតិលេខ៦៧បី ខាងកើតទល់នឹងឈ្មោះ [redacted] ចាន់ធី ខាងលិចទល់នឹងឈ្មោះ [redacted] ម៉ារី មានទីតាំងស្ថិតនៅភូមិវត្ត ឃុំស្រែណូយ ស្រុកវ៉ារិន ខេត្តសៀមរាប។

**ឃ- ចំណុចវិវាទ**

-តើសហចុងចម្លើយពិតជាបានធ្វើអំណោយដី និងផ្ទះ ដែលជាកម្មវត្ថុនៃការទាមទារទៅឲ្យដើមចោទមែនដែរឬទេ?

-តើដើមចោទពិតជាជួយបង់សងបំណុលធនាគារជំនួសសហចុងចម្លើយអស់ប្រាក់ចំនួន ២០.០០០ ដុល្លារអាមេរិកមែនដែរឬទេ?

**នាពេលទាញហេតុផលដោយផ្ទាល់មាត់**

**ដើមចោទ:** ឈ្មោះ [redacted] ខ្មែរហ៊ាង ដោយមានលោកមេធាវី [redacted] ជាអ្នកតំណាងដោយអាណត្តិ បានធ្វើសេចក្តីថ្លែងការណ៍ថា ខ្ញុំសូមរក្សាការទាមទារ និង អង្គហេតុដែលជាមូលហេតុ នៃការទាមទារ ដូចមាននៅក្នុងពាក្យបណ្តឹង និងកំណត់ហេតុនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលលើកទី២ ទុកជាបានការដដែល ។

ចំពោះចំណុចវិវាទទី១ និងទី២ កាលអំឡុងឆ្នាំ២០២០ នាងខ្ញុំបានរៀបអាពាហ៍ពិពាហ៍ជាមួយឈ្មោះ [redacted] ចាន់ពេជ្រ (អតីតប្តី) ត្រឹមត្រូវតាមប្រពៃណី ហើយបានចុះសំបុត្រអាពាហ៍ពិពាហ៍លេខ: ០១៩ សៀវភៅអាពាហ៍ពិពាហ៍ លេខ:០១/២០២០ ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០២០។ ក្រោយពីរៀបអាពាហ៍ពិពាហ៍ រួចឪពុកក្មេកខ្ញុំ ដែលមានឈ្មោះ [redacted] ចន្ទី និង ម្តាយក្មេកឈ្មោះ [redacted] សៀកហ៊ិន បានចែកដីធ្លី (ជាអំណោយ) មួយកន្លែងដែលមានទំហំ៥៥០ម៉ែត្រការ៉េ ជាប្រភេទដីលំនៅឋានដែលមានព្រំប្រទល់ខាងជើងទល់នឹងឈ្មោះ [redacted] សូនី ខាងត្បូងទល់នឹងចំណីផ្លូវជាតិលេខ៦៧បី ខាងកើតទល់ឈ្មោះ [redacted] ចន្ទី ខាងលិច ទល់នឹងឈ្មោះ [redacted] ម៉ារី មានទីតាំងស្ថិតនៅភូមិវត្ត ឃុំស្រែណូយ ស្រុកវ៉ារិន ខេត្តសៀមរាប។

បន្ទាប់ពីឈ្មោះ [redacted] ចន្ទី និង ម្តាយក្មេកឈ្មោះ [redacted] សៀកហ៊ិន បានឲ្យផ្ទះ និងដីមកឲ្យនាងខ្ញុំ និងអតីតប្តីនាងខ្ញុំ នាងខ្ញុំក៏មានគម្រោងបង្កើតមុខរបរថ្មី ហើយក៏បានចាក់ដី និងកែច្នៃផ្ទះនោះបន្ថែម អស់ទឹកប្រាក់ចំនួន ២០.០០០ (ពីរម៉ឺន) ដុល្លារអាមេរិក ដើម្បីបង្កើតមុខរបរថ្មី (បើកម៉ាត លក់ឡេ លក់ខោអាវ)។ ប៉ុន្តែ នាងខ្ញុំ និងអតីតស្វាមីនាងខ្ញុំ មិនមានលុយគ្រប់គ្រាន់ក្នុងការចាក់ដី កែច្នៃផ្ទះ និងបើករបរថ្មី (បើកម៉ាត លក់ឡេ លក់ខោអាវ) នោះទេ ហើយនាងខ្ញុំ និងអតីតប្តី ក៏បានទៅខ្ចីប្លង់ដីរបស់ម្តាយក្មេក ឪពុកក្មេករបស់



Scanned with CamScanner

នាងខ្ញុំឈ្មោះ [redacted] ចន្ធី និង ឈ្មោះ [redacted] សៀកហ៊ុន ដើម្បីខ្ចីលុយធនាគារអេស៊ីលីដា មានទឹកប្រាក់ចំនួន ២០.០០០ (ពីរម៉ឺន) ដុល្លារអាមេរិក។ ហើយជារៀងរាល់ខែនាងខ្ញុំ និងអតីតប្ដីនាងខ្ញុំ ជាអ្នកបង់ប្រាក់សងទៅធនាគារអេស៊ីលីដា។

ក្រោយមកក្នុងអំឡុង ឆ្នាំ២០២១ នាងខ្ញុំបានសាងសង់ផ្ទះ និងរបងអស់ទឹកប្រាក់ប្រហែលចំនួន ២០.០០០ (ពីរម៉ឺន) ដុល្លារអាមេរិក ព្រមទាំងបានកាន់កាប់រួមរស់ជាមួយប្ដី និងកូនស្រីម្នាក់អាយុ៤ខែ នៅលើដីធ្លីនោះ ដោយបើកអាជីវកម្មលក់ខោអាវ រហូតមកដល់ឆ្នាំ២០២៣ នេះ នាងខ្ញុំ និងឈ្មោះ [redacted] ចាន់ពេជ្រ បានលែងលះគ្នា ហើយ ម្ដាយឪពុកក្មេករបស់នាងខ្ញុំបានធ្វើការទាមទារយកដីធ្លីខាងលើត្រឡប់ទៅវិញ ដោយលើកមូលហេតុថា នាងខ្ញុំបានលែងលះជាមួយកូនរបស់គាត់ហើយ និងបានយកសោមកចាក់ បិទទ្វារផ្ទះរបស់នាងខ្ញុំ មិនឲ្យនាងខ្ញុំចូលរស់នៅ និងលក់ខោអាវដូចសព្វរាល់ដងឡើយ។ នៅក្នុងផ្ទះរបស់នាងខ្ញុំនោះរួមមានៈ ឥវ៉ាន់ខោអាវ និងរបស់របរប្រើប្រាស់ជាច្រើន។ យ៉ាងណាមិញទោះបីជានាងខ្ញុំខិតខំព្យាយាមទៅបើកទ្វាផ្ទះ ដើម្បីចូលទៅរស់នៅយ៉ាងណាក៏ដោយ ក៏ឪពុកម្ដាយក្មេក និងបក្សពួកបានរាំងមិនឲ្យនាងខ្ញុំរស់នៅកាន់កាប់ផ្ទះនោះឡើយ។ ម្យ៉ាងវិញទៀត នាងខ្ញុំក៏បានប្ដឹងទៅអាជ្ញាធរភូមិឃុំ ប៉ុន្តែក៏នៅតែពុំមានដំណោះស្រាយដែរ។ ដោយហេតុថា នាងខ្ញុំជាស្ត្រីមេម៉ាយកូនមួយ ទើបតែឆ្លងទន្លេ រាងកាយទន់ខ្សោយ ទើបនាងខ្ញុំដាក់ពាក្យបណ្ដឹងទាមទារដូចក្នុងកម្មវត្ថុខាងលើមកតុលាការ ដើម្បីទាមទាររកយុត្តិធម៌ដល់រូបនាងខ្ញុំ និងកូនស្រី។ ស្នើសុំឲ្យតុលាការពិនិត្យឯកសារដែលជាភស្តុតាងដូចជាៈ សាលាកប័ត្រព័ត៌មាន លេខ ១២១៥/២០ ចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០២០ ចេញដោយលោកមេភូមិវត្ត ឃុំស្រែណូយ ស្រុកវ៉ារិន ខេត្តសៀមរាប។

ចំពោះចំណុចវិវាទទី២ ពុំមានភស្តុតាងបញ្ជាក់ការទាមទារនោះទេ ពីព្រោះរាល់ពេលដល់ថ្ងៃបង់ប្រាក់ទៅធនាគារ នាងខ្ញុំតែងតែប្រគល់ប្រាក់ឲ្យទៅសហចុងចម្លើយដោយផ្ទាល់ដៃ ដើម្បីទៅបង់ធនាគារ។ ដូច្នេះហើយ រាល់ឯកសារទាំងអស់គឺនាងខ្ញុំពុំមាននោះទេ នៅខាងធនាគារគេមិនឲ្យថតចម្លង និងនៅសហចុងចម្លើយ ។

ចំពោះការទាមទារចំណុច គ សំណងការខូចខាត និងសងជំងឺចិត្តចំនួន ៥.០០០ (ប្រាំពាន់) ដុល្លារអាមេរិក ដោយហេតុថា នាងខ្ញុំខាតពេលវេលាក្នុងការរកស៊ី ហើយខូចខាតសំលៀកបំពាក់ និងឥវ៉ាន់ផ្សេងៗទៀតមួយចំនួន ។

**សហចុងចម្លើយ**: ឈ្មោះ [redacted] ចន្ធី ដោយមានលោកមេធាវី [redacted] ជាអ្នកតំណាងដោយអាណត្តិ បានធ្វើសេចក្ដីថ្លែងការណ៍ថា ចំពោះចំណុចវិវាទទី១ និងចំណុចទី២ ខ្ញុំបាទសូមធ្វើសេចក្ដីថ្លែងការណ៍សម្រាប់ការទាញហេតុផលដោយផ្ទាល់មាត់ និង តបទៅនឹងសេចក្ដីថ្លែងការណ៍របស់ដើមចោទដូចតទៅ៖

១. សហចុងចម្លើយពុំធ្លាប់បានធ្វើអំណោយដី និងផ្ទះ ដែលជាកម្មវត្ថុនៃការទាមទារទៅឱ្យដើមចោទទេ ព្រោះបើសហចុងចម្លើយ បានធ្វើអំណោយមែននោះ ដើមចោទ មិនចាំបាច់ទាមទារឱ្យសហចុងចម្លើយ ដូចមាននៅក្នុងកម្មវត្ថុនៃការទាមទារនៃពាក្យបណ្ដឹងនោះទេ។

ដោយហេតុថា៖ ប្រសិនបើសហចុងចម្លើយ ធ្វើអំណោយដី និងផ្ទះ ទំហំ ៥៥០ម៉ែត្រការ៉េឱ្យទៅដើមចោទ គឺ ច្បាស់ណាស់ ត្រូវតែមានលិខិតប្រគល់សិទ្ធិ ឬលិខិតផ្ទេរសិទ្ធិ ឬលិខិតពាក់ព័ន្ធការធ្វើអំណោយ ឬ ប្រទានកម្មដី និងផ្ទះនោះ ហើយបើផ្ទាត់មាត់ត្រូវមានសាក្សីបញ្ជាក់ ស្របទៅតាមច្បាប់ តែមកដល់ពេលនេះ ដើមចោទ នៅ

តែពុំមានភស្តុតាងណាមួយដែលបញ្ជាក់ថា សហចុងចម្លើយធ្លាប់បានធ្វើអំណោយ ឬផ្ទេរសិទ្ធិដី និងផ្ទះ ឱ្យដើមចោទនោះទេ។

២.បន្ទាប់ពីសហចុងចម្លើយខ្ចីប្រាក់ពីធនាគារកន្លងមក ដើមចោទ មិនដែលជួយបង់សងបំណុលធនាគារជំនួសសហចុងចម្លើយទេ រីតតែមិនបានជួយបង់សងហេតុដល់ទៅចំនួន ២ម៉ឺនដុល្លារ ថែមទៀត វិក័យបត្ររបស់ធនាគារ អេស៊ីលីដា ចំនួន ៦៨ សន្លឹក បញ្ជាក់ពី សហចុងចម្លើយ បានបង់សងប្រាក់ទៅធនាគារ អេស៊ីលីដា រហូតមកដល់បច្ចុប្បន្ននេះ។

កាលពីថ្ងៃទី១៨ ខែសីហា ឆ្នាំ២០២២ សហចុងចម្លើយបានដាក់ពាក្យបណ្តឹងប្តឹងដើមចោទ ដើម្បីទាមទារប្រាក់ចំនួន ២០.០០០ ដុល្លាអាមេរិក ដែលដើមចោទបានយកទៅ និងចាកចេញពីផ្ទះបាត់ដំណឹង។ រហូតដល់ថ្ងៃកំណត់ត្រូវសងប្រាក់ធនាគារ ទើបធនាគារជូនដំណឹងមកសហចុងចម្លើយ ដើម្បីឱ្យសហចុងចម្លើយទៅបង់សងប្រាក់ ដោយសារដើមចោទ ពុំអាចទាក់ទងបាន និងពុំបានចូលទៅដោះស្រាយ ឬបង់សងប្រាក់នោះទេ ម៉្យាងទ្រព្យដែលបានដាក់តម្កល់នោះជាទ្រព្យរបស់សហចុងចម្លើយ បើសហចុងចម្លើយមិនបង់ប្រាក់សងទេនោះធនាគារបានឹងប្តឹងទាមទារកាត់យកដីជាកម្មសិទ្ធិ ។

ប្រសិនបើភាគីដើមចោទថាសហចុងចម្លើយបានធ្វើអំណោយ ហើយថាខ្លួនជាអ្នកបង់សងប្រាក់ទៅធនាគារនោះ សូមលើកយកភស្តុតាងមកបញ្ជាក់។ ត្រឹមតែសាលាកប័ត្រព័ត៌មានរបស់ដើមចោទមិនអាចយកមកបញ្ជាក់បានថាជាម្ចាស់កម្មសិទ្ធិបានទេ ឯឯកសារដែលមានពាក្យសុំកាន់កាប់ប្រើប្រាស់ដីធ្លី និងលិខិតផ្ទេរសិទ្ធិកាន់កាប់ដីធ្លី របស់សហចុងចម្លើយដែលបានដាក់ជូនលោកចៅក្រមពិនិត្យនោះគឺបញ្ជាក់បានថា សហចុងចម្លើយពិតជាម្ចាស់កម្មសិទ្ធិលើដីនោះមែន។ ចំពោះសាលាកប័ត្រលេខ ១២១៦/២០ របស់សហចុងចម្លើយដែលបានដាក់ជូនលោកចៅក្រមនោះ ក៏សហចុងចម្លើយមានដែរ ព្រោះរៀងរាល់ឆ្នាំអាជ្ញាធរមូលដ្ឋាន តែងតែចុះស្រង់ទិន្នន័យដីតាមភូមិឃុំ ដើម្បីឲ្យដឹងថាបច្ចុប្បន្ននៅលើដីនោះកំពុងប្រើប្រាស់ធ្វើអ្វី។ អ្វីដែលភាគីអះអាងមកនេះ មិនមានភស្តុតាងណាមួយមកបញ្ជាក់ទេ ។

ស្នើសុំតុលាការពិនិត្យភស្តុតាងដូចជាៈ សាលាកប័ត្រព័ត៌មាន លេខៈ១២១៦/២០ ចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០២០ ស្ថិតនៅភូមិវត្ត ឃុំស្រែណូយ ស្រុកវ៉ារិន ខេត្តសៀមរាប, ពាក្យស្នើសុំកាន់កាប់ដីធ្លីលេខៈ១៣៩០/១២ ចុះថ្ងៃទី០៤ ខែតុលា ឆ្នាំ២០១២, លិខិតផ្ទេរសិទ្ធិកាន់កាប់ដី លេខៈ១៣៩០/១២ ចុះថ្ងៃទី០៤ ខែតុលា ឆ្នាំ២០១២, ពាក្យសុំច្បាប់សាងសង់ ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១៤, កិច្ចសន្យា របស់ឈ្មោះ វ៉ា ចន្ធី ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១៤, វិក័យបត្របង់ប្រាក់ទៅធនាគារចំនួន ៦៨សន្លឹក និងឯកសារពាក់ព័ន្ធនឹងកម្ចីធនាគារ ។

**ដើមចោទៈ** ឈ្មោះ [redacted] ឡេហ៊ាង បានធ្វើសេចក្តីថ្លែងការណ៍តបថា ដោយផ្អែកទៅលើភស្តុតាងដែលសហចុងចម្លើយបានដាក់ជូនមកតុលាការ បង្ហាញច្បាស់ថា ទីតាំងនៃដីធ្លីរវាងនាងខ្ញុំ និងសហចុងចម្លើយគឺចែកដាច់ពីគ្នា ពីព្រោះថា សហចុងចម្លើយមានសាលាកប័ត្រព័ត៌មានកាន់កាប់ដីធ្លីលេខៈ១២១៦/២០ ចំណែកឯនាងខ្ញុំមានសាលាកប័ត្រលេខៈ១២១៥/២០ នេះសបញ្ជាក់ថា សហចុងចម្លើយកំពុងតែកាន់កាប់ទៅលើដីធ្លីរបស់នាងខ្ញុំ ដែលជាអំណោយដែលបានតាំងពីអំឡុងពេលរៀបអាពាហ៍ពិពាហ៍មកម្លេះ។ ពាក់ព័ន្ធនឹងសហចុង



Scanned with CamScanner

ចម្លើយបានថ្លែងការណ៍ថា នាងខ្ញុំបានយកលុយចំនួន ២០.០០០ ដុល្លារអាមេរិក នោះ គឺជាពាក្យមិនពិតសោះ ឡើយ ពីព្រោះ នាងខ្ញុំគ្មានប្រាក់រហូតដល់ ២០.០០០ ដុល្លារអាមេរិក នោះទេ។ នៅពេលដែលនាងខ្ញុំចាកចេញ ពីផ្ទះមក បានយកតែកូនមកជាមួយតែប៉ុណ្ណោះ ហើយសហចុងចម្លើយបានប្តឹងនាងខ្ញុំ មកកាន់សាលាដំបូង ខេត្តសៀមរាប ផងដែរ ប៉ុន្តែ សហចុងចម្លើយបានដកពាក្យបណ្តឹងទៅវិញ ដោយលះបង់ការទាមទារទៅវិញ ។ ពាក់ព័ន្ធនឹងសំណងការខូចខាតចំនួន ៥.០០០ ដុល្លារអាមេរិក នាងខ្ញុំសូមរក្សានូវការទាមទារដដែល ដោយ ហេតុថា សហចុងចម្លើយបានយកសោចាក់បិទទ្វារផ្ទះរបស់នាងខ្ញុំ មិនឲ្យនាងខ្ញុំចូលរស់នៅ និងលក់ខោអាវ ដូចសព្វដង ក្នុងផ្ទះរបស់នាងខ្ញុំនោះរួមមាន ឥវ៉ាន់ ខោអាវ និងរបស់របរប្រើប្រាស់ជាច្រើនទៀត។ ម្យ៉ាងវិញទៀត ធ្វើឲ្យនាងខ្ញុំ ខាតពេលវេលាជាច្រើននៅក្នុងការរកស៊ី ហើយខូចខាតសម្លៀកបំពាក់ និងឥវ៉ាន់ផ្សេងៗមួយចំនួន ទៀត ដែលមាននៅក្នុងផ្ទះរបស់នាងខ្ញុំដែលមានទីតាំងដូចខាងលើនេះ ។

**សហចុងចម្លើយ:** ឈ្មោះ [redacted] ចន្ទី ដោយមានលោកមេធាវី [redacted] ជាអ្នកតំណាងដោយអាណត្តិ បានធ្វើសេចក្តីថ្លែងការណ៍ថា ចំពោះការទាមទារសំណងការខូចខាតចំនួន ៥.០០០ ដុល្លារអាមេរិក ខ្ញុំបានសូម ប្រានចោល ដោយសារ មិនមែនជាកំហុសរបស់សហចុងចម្លើយនោះទេ ។ ចំពោះការថ្លែងការណ៍របស់ដើម ចោទ ថា សាលាកប័ត្រទាំងពីរនេះខុសគ្នា នោះមិនពិតនោះទេ ដោយសារ សហចុងចម្លើយកាន់កាប់នោះគឺមាន សាលាកប័ត្រតែប៉ុណ្ណោះ គឺលេខ:១២១៦ ដែលមានអាជ្ញាធរភូមិឃុំ និងហត្ថលេខា ទទួលស្គាល់តែមួយ ។

## **សំអាងហេតុ**

១- យល់ឃើញថា ពាក្យបណ្តឹង ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០២៣ របស់ដើមចោទឈ្មោះ ចាន់ ឡៃហ៊ាង ធ្វើឡើងត្រឹមត្រូវតាមបញ្ញត្តិមាត្រា៧៤ និង មាត្រា៧៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី។ តុលាការគប្បីមានសមត្ថ កិច្ចវិនិច្ឆ័យលើបណ្តឹងនេះ តាមបញ្ញត្តិមាត្រា៧ ដល់ មាត្រា៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

២- យល់ឃើញថា តាមពាក្យបណ្តឹង ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០២៣ ដើមចោទឈ្មោះ ចាន់ ឡៃហ៊ាង ប្តឹងសុំឲ្យតុលាការឲ្យចេញសាលក្រមដែលមានខ្លឹមសារៈ

ក. បង្គាប់ឲ្យចុងចម្លើយប្រគល់ការកាន់កាប់ដីធ្លី - ផ្ទះមួយកន្លែងដែលមានទំហំ៥៥០ម៉ែត្រការ៉េ ជា ប្រភេទដីលំនៅឋាន ដែលមានព្រំប្រទល់ខាងជើងទល់នឹងឈ្មោះ [redacted] សូនី ខាងត្បូងទល់នឹងចំណីផ្លូវជាតិ លេខ៦៧បី ខាងកើតទល់នឹងឈ្មោះ [redacted] ចាន់ធី ខាងលិចទល់នឹងឈ្មោះ [redacted] ម៉ារី មានទីតាំងស្ថិតនៅភូមិវត្ត ឃុំស្រែណូយ ស្រុកវ៉ារិន ខេត្តសៀមរាប ប្រគល់ទៅឲ្យដើមចោទឈ្មោះ [redacted] ឡៃហ៊ាង។

ខ. បង្គាប់ឲ្យចុងចម្លើយធ្វើនីតិវិធីផ្ទេរការកាន់កាប់ដីធ្លី-ផ្ទះមួយកន្លែងដែលមានទំហំ៥៥០ម៉ែត្រការ៉េ ជាប្រភេទដីលំនៅឋាន ដែលមានព្រំប្រទល់ខាងជើងទល់នឹងឈ្មោះ [redacted] សូនី ខាងត្បូងទល់នឹងចំណីផ្លូវ ជាតិលេខ៦៧បី ខាងកើតទល់ឈ្មោះ វ៉ា ចាន់ធី ខាងលិចទល់នឹងឈ្មោះ [redacted] ម៉ារី មានទីតាំងស្ថិតនៅភូមិ វត្ត ឃុំស្រែណូយ ស្រុកវ៉ារិន ខេត្តសៀមរាប ប្រគល់ទៅឲ្យដើមចោទឈ្មោះ ចាន់ ឡៃហ៊ាង។

គ. បង្គាប់ឲ្យចុងចម្លើយសងសំណងនៃការខូចខាត និងសងជំងឺចិត្តចំនួន ៥.០០០ (ប្រាំពាន់) ដុល្លារអាមេរិក ប្រគល់ទៅឲ្យដើមចោទឈ្មោះ ចាន់ ឡៃហ៊ាង។

ឃ. ប្រាក់ប្រដាប់ក្តី ជាបន្ទុករបស់ចុងចម្លើយ។



Scanned with CamScanner

៣- យល់ឃើញថា មាត្រា ៥៦៨ (និយមន័យ) នៃក្រមរដ្ឋប្បវេណី ចែងថា *"ប្រទានកម្មសំដៅទៅលើកិច្ចសន្យាមួយ ដែលត្រូវមានអានុភាព ដោយភាគីម្ខាងបង្ហាញឆន្ទៈផ្តល់ទៅឱ្យភាគីម្ខាងទៀតនូវទ្រព្យសម្បត្តិ ដោយមិនយកថ្លៃ ហើយភាគីម្ខាងទៀតយល់ព្រមទទួល។"* មាត្រា ៥៧០ (ប្រទានកម្មដែលមិនធ្វើជាលាយលក្ខណ៍អក្សរ) នៃក្រមរដ្ឋប្បវេណីចែងថា *"ទោះបីជាបានធ្វើការសន្យាប្រទានកម្មក៏ដោយ ប្រសិនបើមិនបានធ្វើជាលាយលក្ខណ៍អក្សរស្តីពីប្រទានកម្មទេ ភាគីនៃកិច្ចសន្យាអាចលុបចោលកិច្ចសន្យាដោយដកការបង្ហាញឆន្ទៈនៃការធ្វើប្រទានកម្មវិញបាន។ ប៉ុន្តែ ចំពោះផ្នែកដែលបានអនុវត្តហើយ មិនអាចដកការបង្ហាញឆន្ទៈនៃការធ្វើប្រទានកម្មវិញបានឡើយ។"*

៤- យល់ឃើញថា សេចក្តីកំណត់ចំពោះមាត្រា៥៧០ នៃក្រមរដ្ឋប្បវេណី ពន្យល់ថា *"ជាធម្មតា ប្រសិនបើឆន្ទៈរបស់ទាយកត្រូវបានបង្ហាញតាមរូបភាពជាលាយលក្ខណ៍អក្សរ ការបង្ហាញឆន្ទៈបៀបនេះគឺជាលទ្ធផលនៃការវិនិច្ឆ័យដោយប្រុងប្រយ័ត្នរបស់ទាយក ហើយឆន្ទៈនេះអាចត្រូវបានធ្វើការបញ្ជាក់យ៉ាងច្បាស់លាស់តាមលិខិតជាលាយលក្ខណ៍អក្សរនោះ។ ដោយហេតុនេះ បដិគ្គាហកអាចបង្ខំឱ្យទាយកអនុវត្តនូវប្រទានកម្មបាន។ ក៏ប៉ុន្តែ ចំពោះប្រទានកម្មដែលមិនធ្វើជាលាយលក្ខណ៍អក្សរ មានករណីជាច្រើនដែលទាយកសន្យាធ្វើប្រទានកម្មដោយមិនបានគិតពិចារណាដោយប្រុងប្រយ័ត្ន។ ហេតុដូច្នេះ មាត្រានេះចែងអំពីលទ្ធភាពនៃការដក។"*

៥- យល់ឃើញថា ដើមចោទប្តឹងទាមទារឲ្យសហចុងចម្លើយប្រគល់ការកាន់កាប់ និងធ្វើនីតិវិធីផ្ទេរការកាន់កាប់ដីធ្លី-ផ្ទះ ដែលជាកម្មវត្ថុនៃការទាមទារខាងលើ ដោយផ្អែកលើមូលហេតុថា សហចុងចម្លើយបានធ្វើអំណោយ ឬប្រទានកម្មដី និងផ្ទះនេះមកឲ្យដើមចោទ។ ការទាមទាររបស់ដើមចោទ ត្រូវបានសហចុងចម្លើយបដិសេធ ដោយសហចុងចម្លើយបានអះអាងថា សហចុងចម្លើយពុំបានធ្វើអំណោយ ឬប្រទានកម្មដី និងផ្ទះខាងលើទៅឲ្យដើមចោទឡើយ។ ត្រង់ចំណុចនេះ ដើមចោទមានកាតព្វកិច្ចបញ្ជាក់ដោយកស្តុតាង។ ដើមចោទបានផ្តល់កស្តុតាង ជូនតុលាការពិនិត្យ គឺសាលាកប័ត្រព័ត៌មាន លេខ១២១៥/២០ ចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០២០ ចេញដោយលោកមេភូមិវត្ត ឃុំស្រែណូយ ស្រុកវ៉ារិន ខេត្តសៀមរាប។ តាមការពិនិត្យឃើញថា សាលាកប័ត្រព័ត៌មាននេះមិនមែនជាលិខិតប្រទានកម្មជាលាយលក្ខណ៍អក្សរឡើយ ពីព្រោះពុំមានហត្ថលេខា ឬស្នាមមេដៃទទួលស្គាល់ដោយសហចុងចម្លើយ ដែលបញ្ជាក់អំពីឆន្ទៈធ្វើអំណោយ ឬប្រទានកម្មឡើយ។ ផ្ទុយទៅវិញ តាមការពិនិត្យកស្តុតាង ដែលសហចុងចម្លើយបានដាក់ជូនតុលាការ រួមមាន សាលាកប័ត្រព័ត៌មាន លេខៈ១២១៦/២០ ចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០២០, ពាក្យស្នើសុំកាន់កាប់ប្រើប្រាស់ដីធ្លីលេខៈ១៣៩០/១២ ចុះថ្ងៃទី០៤ ខែតុលា ឆ្នាំ២០១២, លិខិតផ្ទេរសិទ្ធិកាន់កាប់ដី លេខៈ១៣៩០/១២ ចុះថ្ងៃទី០៤ ខែតុលា ឆ្នាំ២០១២ និងពាក្យសុំច្បាប់សាងសង់ ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១៤ ឃើញថា សហចុងចម្លើយមានសិទ្ធិកាន់កាប់លើដីទំហំ ១.៣០០ ម៉ែត្រការ៉េ ដែលមានលិខិតទទួលស្គាល់ដោយអាជ្ញាធរភូមិឃុំ។

៦- យល់ឃើញថា ដើមចោទបានអះអាងថា ខ្លួនបានចេញប្រាក់សងបំណុលទៅធនាគារជំនួសសហចុងចម្លើយចំនួន ២០.០០០ ដុល្លារអាមេរិក ប៉ុន្តែដើមចោទពុំមានកស្តុតាងបញ្ជាក់ ដាក់ជូនតុលាការពិនិត្យឡើយ។ ផ្ទុយទៅវិញ តាមការពិនិត្យកស្តុតាងជា វិក្កយបត្ររបស់ធនាគារអេស៊ីលីដា ដែលសហចុងចម្លើយបានដាក់ជូនតុលាការ ឃើញថា សហចុងចម្លើយបានបង់ប្រាក់ទៅធនាគារ។

៧- យល់ឃើញថា តាមសំអាងហេតុចំណុចខាងលើ តុលាការពុំគប្បីសម្រេចតាមការទាមទារទី១ ការទាមទារទី២ និងការទាមទារទី៣ របស់ដើមចោទ ដូចក្នុងពាក្យបណ្តឹង ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០២៣ ឡើយ។



Scanned with CamScanner

៨- យល់ឃើញថា តាមមាត្រា ៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ភាគីដែលចាញ់ក្តី។ ដូច្នេះ គប្បីតុលាការសម្រេចឲ្យដើមចោទឈ្មោះ [redacted] ឡៃហ៊ាង ទទួលបន្ទុកលើប្រាក់ប្រដាប់ក្តី។

**<u>សេចក្តីសម្រេចបញ្ចប់</u>**

**១**. ច្រានចោលការទាមទារចំណុចទី១ ចំណុចទី២ និងចំណុចទី៣ នៃពាក្យបណ្តឹងចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០២៣ របស់ដើមចោទឈ្មោះ [redacted] ឡៃហ៊ាង។

**២**. ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ដើមចោទឈ្មោះ [redacted] ឡៃហ៊ាង។

ថ្ងៃសុក្រ ៧រោច ខែជេស្ឋ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨

សៀមរាប, ថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០២៤

**ចៅក្រម**

ហត្ថលេខា និងត្រា: [redacted]

---

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃសុក្រ ៧រោច ខែជេស្ឋ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨

សៀមរាប, ថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០២៤

បានឃើញ

**ចៅក្រម**

[redacted]

**ក្រឡាបញ្ជី**

[redacted]



Scanned with CamScanner